កំណត់សម្គាល់អំពីសារតា

# វិធីគាំទ្រជនរងគ្រោះ នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ( GBV ) នៅពេលដែលគ្មាន តួអង្គដែលធ្វើការងារផ្នែក GBV ក្នុងតំបន់របស់អ្នក៖

## កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំជាជំហានៗសម្រាប់អ្នកអនុវត្តការងារមនុស្សធម៌-សំណៅ ២.0

**កាលពីខែកញ្ញា ឆ្នាំ២០១៥ គោលការណ៍ណែនាំគណៈកម្មាធិការអន្តរស្ថាប័នចំពោះកិច្ច ហៅកាត់ថា** IASC **សម្រាប់ធ្វើសមាហរណកម្មអន្តរាគមន៍ អំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅក្នុងបរិបទនៃមនុស្សធម៌** (គោលការណ៍ណែនាំស្តីអំពី GBV) ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់។ ក្នុងឆ្នាំ២០១៦ និង ២០១៧ ក្រុមគាំទ្រការអនុវត្តគោលការណ៍ណែនាំស្តីអំពីGBV បានផ្តល់ការបណ្តុះបណ្តាល ជូនដល់អ្នកអនុវត្តការងារមនុស្សធម៌ ជាង ២៥00នាក់នៅក្នុងវិស័យចំនួន១១និងប្រទេសចំនួន១៨ អំពីរបៀបកាត់បន្ថយហានិភ័យពាក់ព័ន្ធនឹង អំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងកម្មវិធីរបស់ពួកគេ។

នៅក្នុងបរិបទនិង វិស័យផ្សេងៗគ្នា អ្នកចូលរួមការបណ្តុះបណ្តាលបានបង្ហាញឱ្យដឹងអំពីចំណាប់អារម្មណ៍និងសេចក្តីត្រូវការរបស់ពួកគេសម្រាប់ធនធានចំណេះធ្វើច្បាស់លាស់ **អំពីរបៀបគាំទ្រជនរងគ្រោះនៃ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ( GBV ) នៅពេលដែលគ្មានតួអង្គធ្វើការងារផ្នែក GBV(រួមទាំងការបញ្ជូន ឬអ្នកឯកទេស/ជនបង្គោល GBV ) នៅក្នុងតំបន់របស់ពួកគេ។** ក្រោយពេលពិគ្រោះជាមួយអ្នកអនុវត្តការងារនិង យន្តការដទៃទៀត វាបានបង្ហាញឱ្យឃើញច្បាស់ថា បញ្ហាប្រឈមនេះកើតឡើងនៅក្នុងបរិបទជា ច្រើននិង រវាងតួអង្គជាច្រើនប្រភេទផ្សេងៗគ្នា។

ដើម្បីបំពេញចន្លោះប្រហោងនេះ ក្រុមការងារចម្រុះដែលរៀប ចំឡើងដោយក្រុមការងារ សម្រាប់គោលការណ៍ណែនាំស្តីអំពី GBV និង វិស័យការងារទទួលខុសត្រូវ របស់ GBV បានអភិវឌ្ឍ កញ្ចប់ធនធានមួយអំពីរបៀបគាំទ្រ ជនរងគ្រោះនៃ GBV នៅពេលដែលគ្មានការបញ្ជូន ឬ ជន បង្គោល GBV ( “កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ“ ) ក្នុងលក្ខណៈជាមគ្គុទ្ទេសសម្រាប់ភ្ជាប់ទៅនឹង គោលការណ៍ណែនាំស្តីអំពីGBV។ កញ្ចប់ធនធាននេះត្រូវបានបង្កើតឡើងដោយប្រើប្រាស់ ជំនាញ ឯកទេសពី សមាជិកក្រុមការងារ អ្នកត្រួតពិនិត្យពីខាងក្រៅនិងអ្នកចូលរួមនៅក្នុងការពិគ្រោះយោបល់តាំងពីខែកញ្ញាឆ្នាំ២០១៧ រហូតដល់ ខែកុម្ភៈ ឆ្នាំ២០១៨។ បន្ថែមពីនេះទៀត ធនធាននេះ មានសង្គតភាពទៅនឹងឧបករណ៍សកលដែលមានស្រាប់ ដូចជាឯកសារភ្ជាប់របស់ GBV នៃកម្រងជម្រក ( Shelter Cluster’s GBV Constant Companion ) និងគោលការណ៍ណែនាំស្តីពីការថែទាំកុមារ រងគ្រោះនៃអំពើរំលោភបំពានផ្លូវភេទរបស់ IRC/UNICEF។

**កញ្ចប់ធនធានកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ សំណៅខែកុម្ភៈ ឆ្នាំ២០១៨**រួមមានសំណៅជាឯកសារ បោះពុម្ព សំណៅជាកម្មវិធីតាមប្រព័ន្ធ អនឡាញនិង កម្មវិធីតាមទូរស័ព្ទចល័ត ជាភាសា អារ៉ាប់ អង់គ្លេស បារាំង និងអេស្ប៉ាញ។

### អំពីគោលការណ៍ណែនាំស្តីអំពី GBV

គោលការណ៍ណែនាំស្តីអំពី GBV ឆ្នាំ២០១៥ (ដែលត្រូវបានកែសម្រួលពីសំណៅ ឆ្នាំ ២00៥ )គឺជាឧបករណ៍មួយដែលបានធ្វើតេស្តសាកល្បងនៅទីកន្លែងជាក់ស្តែង ដែលផ្តល់នូវសេចក្តីណែនាំសម្រាប់តួអង្គដែលធ្វើការងារមនុស្សធម៌និង សហគមន៍រងផលប៉ះពាល់ពីជម្លោះ និង គ្រោះមហន្តរាយ អំពីចំណាត់ការចាំបាច់នានាដើម្បីកាត់បន្ថយ ហានិភ័យពាក់ព័ន្ធនឹង អំពើហិង្សាទាក់ទងនឹងយេនឌ័រ ( GBV ) ដែលនឹងនាំឱ្យកម្មវិធី នានាកាន់តែមានសុវត្ថិភាពនិងប្រសិទ្ធភាព។ គោលការណ៍ណែនាំស្តីពី GBV គឺសម្រាប់ អ្នកដែលពុំមានឯកទេសផ្នែក GBV ដែលអាចនឹងគប្បីធ្វើសកម្មភាពនៅក្នុងប្រតិបត្តិការ ប្រចាំថ្ងៃក្នុងវិស័យការងាររបស់ពួកគេដើម្បីកាត់បន្ថយហានិភ័យទាក់ទងនឹងGBV។យុទ្ធសាស្រ្តអនុវត្តរយៈពេល៣ឆ្នាំ កំពុងត្រូវបានអនុវត្តដើម្បីបង្កើនកម្រិតនៃចំណាប់អារម្មណ៍ ការយល់ដឹង និងការទទួលយកគោលការណ៍ណែនាំស្តីពី GBV។

### តើគោលដៅនៃកញ្ចប់ធនធានកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ គឺជាអ្វី ?

គោលដៅនៃកញ្ចប់ធនធាននេះគឺដើម្បីផ្តល់ឱ្យអ្នកអនុវត្តការងារមនុស្សធម៌ទាំងអស់នូវព័ត៌មានជាក់ស្តែង ក្នុងលក្ខណៈមួយដែលងាយអនុវត្តនិងងាយយកតាមខ្លួនអំពី៖

---→ របៀបគាំទ្រជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រដែលបានប្រាប់អ្នក ឱ្យដឹងក្នុងបរិបទមួយដែល **គ្មានតួអង្គ ដែល ធ្វើការងារផ្នែកអំពើហិង្សាទាក់ទងនឹងយេនឌ័រ** (រួមទាំងច្រកបញ្ជូន ឬជនបង្គោល GBV )**នៅក្នុងតំបន់របស់អ្នក។**

កញ្ចប់ធនធាន ប្រើប្រាស់បទដ្ឋានសកលស្តីពីការផ្តល់កិច្ច គាំទ្រមូលដ្ឋាននិងព័ត៌មានជូនជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដោយមិនបង្កឱ្យមានគ្រោះថ្នាក់បន្ថែមទៀត។ យើងលើកទឹកចិត្តឱ្យកែសម្រួលធនធាននេះ ឱ្យស្របតាមបរិបទក្នុងមូលដ្ឋានរបស់អ្នកដោយមានការគាំទ្រពីអ្នកឯកទេសផ្នែក GBV។

### តើនៅក្នុងកញ្ចប់ធនធានកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ មានអ្វីខ្លះ ?

**១. កំណត់សម្គាល់អំពីសារតានេះ**
គឺដើម្បីណែនាំឱ្យស្គាល់អំពីធនធាន និងផ្តល់សារគន្លឹះសំខាន់ៗសម្រាប់ស្វែងរកមតិគាំទ្រ និងការសម្របសម្រួល។

**២. ឯកសារណែនាំសម្រាប់អ្នកប្រើប្រាស់**
ដែលផ្តោតលើប្រធានកម្មវិធី អ្នកសម្របសម្រួលបច្ចេកទេស ប្រធានក្រុមនិងអ្នកអនុវត្តការងារស្រដៀងគ្នាដទៃទៀតក្នុងគ្រប់វិស័យទាំងអស់ដើម្បីជួយផ្តល់ការណែនាំនិងកសាងសមត្ថភាក្រុមការងាររបស់ពួកគេក្នុងការប្រើប្រាស់កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំព្រមទាំងគាំទ្រជនរងគ្រោះនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ក្នុងករណីដែលជនរងគ្រោះបានប្រាប់ឱ្យដឹងឬស្វែងរកកិច្ចគាំទ្រពីពួកគេ។

(over)

**៣. កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ** កំណត់គោលដៅចំពោះអ្នកផ្ដល់សេវាជួរមុខ នៅគ្រប់កម្រង/វិស័យទាំងអស់ ដើម្បីប្រើប្រាស់ជាឯកសារយោងដ៏ងាយស្រួលអំពីរបៀបគាំទ្រជនរងគ្រោះនៃ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រសិនបើជនរងគ្រោះម្នាក់ស្វែងរក កិច្ចគាំទ្រពីពួកគេក្នុងបរិបទមួយដែលគ្មានតួអង្គដែល ធ្វើការងារផ្នែក GBV ឬមិនមានច្រកបញ្ជូននៅក្នុងតំបន់។

**តើនរណាអាចប្រើប្រាស់កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំបាន?** កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ ត្រូវបានកំណត់គោលដៅសម្រាប់អ្នកដែលពុំមានឯកទេសផ្នែក GBV ដែលស្ថិតនៅជួរមុខកំពុងផ្ដល់សេវាជូនសហគមន៍រងផលប៉ះពាល់ រួមទាំងអ្នកលើកកម្ពស់អនាម័យ បុគ្គលិកសុខភាព សហគមន៍ប្រធានគ្រប់គ្រងជំរុំ ជនបង្គោលទទួលបន្ទុកកិច្ច ការពារ។ល។

**តើមានអ្វីខ្លះនៅក្នុងកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំ?** កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះត្រូវបានរៀបចំឡើងសម្រាប់ប្រើប្រាស់ជាធនធានមួយ សម្រាប់អនុវត្ត នៅពេលដែលជនរងគ្រោះប្រាប់អំពីបទពិសោធន៍របស់ពួកគេឱ្យអ្នកអនុវត្ត ការងារ មនុស្សធម៌ណាម្នាក់បានដឹង។ កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះរួមមានឯកសារយោង រហ័ស តារាងគំនូសបំព្រួញដែលងាយអានអំពីអ្វីដែល ត្រូវធ្វើ និងមិនត្រូវធ្វើ និងការចង្អុលបង្ហាញអំពីបញ្ជីសកម្មភាពជាជំហានៗ ដោយអនុវត្តតាមក្របខ័ណ្ឌនៃការរៀបចំមើល ស្ដាប់ និងភ្ជាប់ទំនាក់ទំនង។

កូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះបាន បញ្ចូលការពិចារណា សម្រាប់កុមារ និងក្មេងជំទង់ក្រុមដែលមានទំនោរផ្លូវភេទដែលងាយរងគ្រោះ ឬក្រុមស្រឡាញ់ភេទដូចគ្នា (LGBTQI) ជនរងគ្រោះដែលមានពិការភាព និងជនរងគ្រោះជាបុរស។

**តើខ្ញុំអាចស្វែងរកកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះនៅឯណា?**

---→ **តាមអនឡាញ**នៅឯលើគេហទំព័រ www.gbvguidelines.org និង www.gbvaor.net ជាសំណៅដែលមានកម្រិតភាពច្បាស់ខ្ពស់ និងទាបសម្រាប់ធ្វើការបោះពុម្ព។

---→ **ទាញយកពី** Google Play ឬ the iTunes store។ ស្វែងរក “GBV Pocket Guide.”

**សៀវភៅមគ្គុទេសក៍នេះបានកែសម្រួលឱ្យស្របជាមួយបរិបទកម្ពុជា** *បកប្រែជាភាសាខ្មែរ និងបោះពុម្ពផ្សាយដោយអង្គការយូនីសេហ្វប្រចាំនៅកម្ពុជា ដោយផ្អែកលើច្បាប់ដើមជាភាសាអង់គ្លេស និងជាធនធានសកលដែលអន្តរស្ថាប័នបានអនុម័ត។*

## សារគន្លឹះសំខាន់ៗសម្រាប់ការស្វែងរកមតិគាំទ្រ និងការសម្របសម្រួល

**១. ការធ្វើសមាហរណកម្មវិធានការកាត់បន្ថយហានិភ័យ GBVដូចជាវិធានការណ៍នៅក្នុងគោលការណ៍ណែនាំ ស្ដីពី GBV របស់ IASC មិនគ្រាន់តែជាការទទួលខុសត្រូវស្នូលរបស់គ្រប់តួអង្គ ដែលធ្វើការងារផ្នែកមនុស្សធម៌ទាំងអស់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជួយធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធ ភាពនៃការឆ្លើយតបផ្នែក មនុស្សធម៌ក្នុងគ្រប់វិស័យទាំងអស់ផងដែរ។**

ក. យោងតាមគោលការណ៍នៃ “ការមិនបង្កគ្រោះថ្នាក់” និង ចំណុចស្នូលនៃសេចក្ដីថ្លែងការណ៍ស្ដីពីកិច្ចការពាររបស់ IASC រាល់តួអង្គដែលធ្វើការងារផ្នែកមនុស្សធម៌ ក្នុងគ្រប់វិស័យទាំងអស់ត្រូវទទួលខុសត្រូវរៀបចំ និងអនុវត្តកម្មវិធីរបស់ពួកគេក្នុងលក្ខណៈមួយដែលកាត់បន្ថយហានិភ័យឱ្យបានជាអតិបរមា និង ធានាចំពោះលទ្ធភាពក្នុងការទទួលបានសម្រាប់ក្រុមងាយរងគ្រោះ។

ខ. នៅពេលដែលកម្មវិធីកាន់តែមានសុវត្ថិភាព និង កាន់តែងាយស្រួលក្នុងការទទួលបាននឹងនាំឱ្យមនុស្សកាន់តែច្រើនទទួលបានប្រយោជន៍ ហើយលទ្ធភាពជារួមមានភាពប្រសើរឡើង។ ដោយឡែក ការខកខានក្នុងការដោះស្រាយបញ្ហាកង្វល់ទាក់ទងនឹង GBV ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព នៃអន្តរាគមន៍ផ្នែកមនុស្សធម៌នៅគ្រប់វិស័យ ទាំងអស់។

**២. វិសមភាពយេនឌ័រដែលមានកន្លងមក ធ្វើឱ្យស្ត្រី និងកុមារី ងាយរងគ្រោះជាពិសេសនៅក្នុងវិបត្តិប្រភេទនេះ ដោយបង្កើនការប្រឈមរបស់ពួកគេទៅនឹង GBV ជាច្រើនទម្រង់** រួមទាំងអំពើហិង្សាផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ អាពាហ៍ពិពាហ៍ដោយបង្ខំ ការកេងប្រវ័ញ្ចនិងការរំលោភផ្លូវភេទ។

ក. នៅពេលដែលគ្រួសារមិនអាចទទួលបាននូវសេចក្ដីត្រូវការមូលដ្ឋានរបស់ខ្លួនស្ត្រី និងកុមារីត្រូវបានបង្ខំឱ្យប្រើប្រាស់ យន្តការដោះស្រាយប្រកបដោយគ្រោះថ្នាក់ដែលបង្កើនការប្រឈមរបស់ពួកគេទៅនឹង GBV។

ខ. នៅពេលដែលស្ត្រីនិងកុមារី មិនត្រូវបានផ្ដល់ឱកាសសម្រាប់ការចូលរួមប្រកបដោយអត្ថន័យ សេចក្ដីត្រូវការ និងការទទួលបានសេវារបស់ពួកគេ រមែងតែងមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការផ្ដល់ ជំនួយមនុស្សធម៌។

**ការក្រឡេកមើលទៅមុខ៖** ក្រុមការងារកំពុងស្វែងរកវិធីផ្ដល់ធនធានបន្ថែមទៀត សម្រាប់សេណារីយ៉ូដែលមានសេវាចល័ត សេវាដែលតម្រូវឱ្យមានការដឹកជញ្ជូនដើម្បីទទួលបានសេវា ឬសេវាទូរគមនាគមន៍ដូចជា បណ្ដាញទូរស័ព្ទទាន់ហេតុការណ៍ឬការជជែកតាមអនឡាញដែលរក្សាការសម្ងាត់។ អ្នកឯកទេសផ្នែក GBV ក៏កំពុងស្វែងរកគំរូនៃការផ្ដល់សេវាថ្មី ដើម្បីឆ្លើយតបបង្ការនិងកាត់បន្ថយ GBV ផងដែរ។ ក្រុមការងារចម្រុះ ក៏កំពុងខិតខំកសាងឧបករណ៍ និងធនធានបន្ថែមទៀតសម្រាប់ផ្ដល់ជូនទៅតាមសេចក្ដីត្រូវការទាំងនេះផងដែរ។

**ការចូលរួម៖** ប្រសិនបើអ្នកចាប់អារម្មណ៍ក្នុងការអនុវត្តកូនសៀវភៅមគ្គុទ្ទេសក៍ណែនាំនេះនៅក្នុង តំបន់របស់អ្នកឬចូលរួមឱ្យបានកាន់តែខ្លាំង ក្នុងការកាត់បន្ថយហានិភ័យ GBV នៅក្នុង កិច្ចសន្ទនា អំពីស្ថានភាពគ្រោះអាសន្ន សូមទាក់ទងតាមអ៊ីមែល៖ gbv.guidelines@gmail.com។

**សេចក្ដីថ្លែងអំណរគុណ៖** ក្រុមការងារសូមថ្លែងអំណរគុណដល់កិច្ចគាំទ្របច្ចេកទេស និងកិច្ចគាំទ្រសម្របសម្រួលដ៏ធំធេងពីអ្នកត្រួតពិនិត្យខាងក្រៅ និងអ្នកចូលរួមពិគ្រោះយោបល់ដែល បាន ចូលរួមរៀបចំសេចក្ដីព្រាងកញ្ចប់ធនធាននេះឡើង ក្នុងនោះរួមមាន ACF, កម្រងសម្របសម្រួល និងគ្រប់គ្រងជំរុំ (Camp Coordination and Camp Management Cluster), វិស័យនៃការ ទទួលខុសត្រូវផ្នែកកិច្ចការពារកុមារ, ក្រុមការងារអន្តរទីភ្នាក់ងារស្ដីពីសុខភាពបន្តពូជនៅពេលមានវិបត្តិ, គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម, IRC, សម្ព័ន្ធអៀកឡង់ស្ដីពីអំពើហិង្សាទាក់ទង នឹងយេនឌ័រ, IOM, សាលារៀនផ្នែកអនាម័យ និងឱសថត្រូពិកនៃទីក្រុងឡុងដ៍, OXFAM,កម្រងជម្រក, Trócaire,UNFPAក្នុងតំបន់ស៊េរីទាំងមូល,UNHCR, UNICEF ស៊ូដង់ខាងត្បូង,កម្រងផ្នែកទឹកនិងអនាម័យ (WASH Cluster), អង្គការទស្សនៈពិភពលោកស៊ូដង់ភាគខាងត្បូង, WFP ស៊ូដង់ភាគខាងត្បូង, គណៈកម្មការស្ត្រីភាសខ្លួន។